# ថ្នាំលេបវ៉ាក់ស៊ីនគ្រុនស្វិតដៃជើង (OPV)

## អ្វីៗ ដែល អ្នក ត្រូវការ ដឹង

## 1 តើរោគគ្រុនស្វិតដៃជើង (POLIO) ជាអ្វី?

គ្រុនស្វិតដៃជើងជាជម្ងឺបណ្ដាលមកពីមេរោគវីរូស។ វាអាចចូលក្នុងខ្លួនកូនក្មេង(មនុស្សធំ)តាមមាត់។ ជួនកាលវាមិនធ្វើទុក្ខធ្ងន់ធ្ងរទេ។ ប៉ុន្តែជួនកាលវាបណ្ដាលឲ្យ*ពិការ*(កម្រើកដៃជើងមិនបាន)។ វាអាចសម្លាប់អ្នកដែលកើតរោគនេះ,ជាធម្មតាអាចខូចសាច់ដុំដែលជួយឲ្យដកដង្ហើម។

គ្រុនស្វិតដៃជើងធ្លាប់កើតច្រើនក្នុងសហរដ្ឋ។ វាធ្វើឲ្យពិការហើយស្លាប់មនុស្សរាប់ពាន់អ្នកក្នុងមួយឆ្នាំៗមុនពេលយើងមានថ្នាំវ៉ាក់ស៊ីន។

## 2 ហេតុអ្វីចាក់ថ្នាំវ៉ាក់ស៊ីន?

**ថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើងអាចការពាររោគគ្រុនស្វិតដៃជើង។**

ប្រវត្តិសាស្ត្រ: កាល១៩១៦ រោគគ្រុនស្វិតដៃជើងរាលដាល ក្ន ងសហរដ្ឋ, ស្លាប់មនុស្ស៦០០០នាក់ និងពិការ២៧០០០នាក់ទៀត។ នៅដើមឆ្នាំ១៩៥០ប្លាយ គឺមានច្រើន ជាង២០០០០នាក់ដែល កើតរោគគ្រុនស្វិតដៃជើងរាល់ឆ្នាំ។ ការចាក់ថ្នាំគ្រុនស្វិតដៃជើង ត្រូវ ចាប់ផ្ដើមនៅឆ្នាំ១៩៥៥។ ដល់ឆ្នាំ១៩៦០រោគនេះបានថយចុះទៅ ប្រមាណ ៣០០០នាក់ ហើយនៅឆ្នាំ១៩៧៩ គឺមានតែ ប្រមាណ១០ នាក់ទេ។ ការជោគជ័យនៃថ្នាំវ៉ាស៊ីនគ្រុនស្វិតដៃជើងក្នុងសហរដ្ឋ និងប្រទេសឯទៀតបានទប់ស្កាត់រោគគ្រុនស្វិតដៃជើងក្នុងពិភពលោក។

សព្វថ្ងៃ: ឥតមានរោគគ្រុនស្វិតដៃជើងត្រូវបានរាយការណ៍ឡើងនៅសហរដ្ឋទេក្ន ងរវាង២០ឆ្នាំហើយ។ ប៉ុន្តែជម្ងឺនេះនៅមានកន្លែងខ្លះក្នុងពិភពលោកនៅឡើយ។ វាមានមនុស្សតែម្នាក់ទេ ក៏អាចនាំជម្ងឺនេះមកវិញបានដែរ បើសិនជាយើងមិនការពារដោយ ចាក់ថ្នាំ។ បើសិនជាការប្រឹងប្រែង បំបាត់ជម្ងឺនេះពីពិភពលោកបាន, ពេលនោះយើងមិនចាំបាច់ត្រូវការ ចាក់ថ្នាំគ្រុនស្វិតដៃជើងទៀតទេ។ ទម្រាំទៅដល់ពេលនោះ យើងត្រូវតែចាក់ថ្នាំឲ្យកូនរបស់យើង។

## 3 ពីរប្រភេទនៃថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើង

**មានពីរប្រភេទនៃថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើង:**

IPV (ថ្នាំវ៉ាក់ស៊ីនប្រឆាំងមេរោគគ្រុនស្វិតដៃជើង): ចាក់ម្ជុល
IPV គឺជាថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើងតម្រូវឲ្យប្រើស្ទើរតែគ្រប់គ្នាក្នុងសហរដ្ឋ។

OPV (ថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើងសំរាប់លេប): បន្តក់,តាមមាត់។ រហូតដល់ឥលូវ OPV បានប្រើច្រើនសំរាប់កូនក្មេងក្នុងសហរដ្ឋ។ ប៉ុន្តែវាមិនត្រូវបានតម្រូវឲ្យប្រើទៀតទេពីពេលនេះទៅ។ *វាលើកលែងតែក្នុងកាលៈទេសៈបានដាក់កម្រិត។* OPV ជួយយើងឲ្យផុតពីប្រទេសកើតរោគគ្រុនស្វិតដៃជើង។ ហើយវាត្រូវបានប្រើច្រើនក្នុងពិភពលោក។

ថ្នាំវ៉ាក់ស៊ីនទាំងពីរយ៉ាងបញ្ឈប់រោគគ្រុនស្វិតដៃជើង, តែ OPVគឺជួយមិនឲ្យជម្ងឺឆ្លងទៅអ្នកផ្សេង។

ម្យ៉ាងវិញ,មានតែមនុស្សពីរបីនាក់ទេ(ម្នាក់រវាង២,៤លាននាក់) OPVបណ្ដាលឲ្យកើតប៉ូលីអូ។ ដោយសារការកើតជម្ងឺគ្រុនស្វិតដៃជើងតិចតួចក្នុងសហរដ្ឋ គ្រូពេទ្យជំនាញជឿជាក់ថា ការប្រើថ្នាំលេបមិនសូវល្អទេ, *ការចាក់ថ្នាំគ្រុនស្វិតដៃជើងដែលយើងឥលូវនេះប្រើអាចទប់ស្កាត់ការកើតជម្ងឺគ្រុនស្វិតដៃជើងបាន។*

កូនសៀវភៅវ៉ាក់ស៊ីននេះគឺអំពីការប្រើថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើងតាមមាត់។ មន្ទីរពេទ្យអ្នកអាចផ្ដល់ពត៌មានកូនសៀវភៅវ៉ាក់ស៊ីនចំពោះថ្នាំវ៉ាក់ស៊ីនការពារជម្ងឺគ្រុនស្វិតដៃជើង, (IPV)។

## 4 តើនរណាគួរលេបថ្នាំគ្រុនស្វិតដៃជើង (OPV) និងពេលណា?

ការប្រើថ្នាំលេបគ្រុនស្វិតដៃជើងគេមិនតម្រូវឲ្យប្រើទូទៅទៀតទេ (OPV) ក្នុងសហរដ្ឋ។ វាលើកលែងតែប្រើក្នុងកាលៈទេសៈចាំបាច់ប៉ុណ្ណោះ:

(1) ក្រុមដើរកំចាត់ជម្ងឺដើម្បីបង្ក្រាបរោគគ្រុនស្វិតដៃជើងរាលដាល។

(2) ក្មេងៗមិនធ្លាប់ចាក់ថ្នាំគ្រុនស្វិតដៃជើងដែលគ្រោងធ្វើដំណើររវាង៤អាទិត្យទៅកាន់ប្រទេសមានជម្ងឺគ្រុនស្វិតដៃជើងច្រើន។ ក្មេងទាំងនេះអាចលេបថ្នាំ (OPV) ជំនួស១ម្ជុលលើកទី១។

(3) កូនក្មេងដែលម្ដាយមិនព្រមឲ្យចាក់ថ្នាំតាមគេតម្រូវ។ ក្មេងទាំងគួរចាក់ថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើងឲ្យបានពីរម្ជុលតាមលេខរៀង ប៉ុន្តែអាចលេបថ្នាំសំរាប់ថ្នាំលើកទីបីឬទីបួន,ឬទាំងពីរលើក។

(4) មនុស្សដែលប្រតិកម្មខ្លាំងទៅនឹងអង់ទីប៊ីយូទិកនីអូមីស៊ិន, ស្រ្តិបតូមីស៊ិន,ឬប៉ូលូមីស៊ិន ពB, ឬក៏មនុស្សដែលមានការប្រតិកម្មខ្លាំងដល់ជីវិតចំពោះថ្នាំចាក់ប៉ូលីអូ (IPV)។ មនុស្សទាំងនេះអាចទទួលថ្នាំលេបគ្រុនស្វិតដៃជើងវិញ។

**បើសិនអ្នកឬកូនរបស់អ្នកដូចនៅក្នុងចំណោម៤ក្រុមខាងលើណាមួយ, ចូរសួរទៅពេទ្យរបស់អ្នកថានៅពេលណាថ្នាំវ៉ាក់ស៊ីនត្រូវបានឲ្យ។ ចូរសួរអំពីការគ្រោះថ្នាក់នៃថ្នាំវ៉ាក់ស៊ីនគ្រុនស្វិតដៃជើងផងដែរមុននឹងទទួលថ្នាំលេបគ្រុនស្វិតដៃជើង, OPV។**

OPV ប្រហែលជាឲ្យលេបជាមួយពេលថ្នាំវ៉ាក់ស៊ីនផ្សេងៗទៀត។

## 5 មនុស្សខ្លះគួរតែកុំលេបថ្នាំគ្រុនស្វិតដៃជើង (OPV) ឬគួររង់ចាំសិន

អ្នកទាំងនេះគួរតែកុំប្រើគ្រុនស្វិតដៃជើងលេប(OPV):

- នរណាម្នាក់ដែលធ្លាប់ប្រើថ្នាំស្ទើរ៉យ ឬក៏ថ្នាំផ្សេងៗទៀត ដែលប៉ះពាល់ដល់ប្រព័ន្ធការពារមេរោគ។
- នរណាម្នាក់ដែលមានរោគមហារីកឬកំពុងទទួលព្យាបាលវិធីគីមី។
- នរណាម្នាក់ដែលកើតអេដស៍ឬមានមេរោគអេដស៍, ឬជម្ងឺមួយដែលប៉ះពាល់ដល់ប្រព័ន្ធការពារមេរោគ។
- បើសិននរណាម្នាក់ដូចនៅក្នុងបីក្រុមនេះនឹងជួរកន្ទបកូនក្មេង ឬនៅក្បែរក្មេងចាក់ថ្នាំវ៉ាក់សាំងគ្រុនស្វិតដៃជើង, ក្មេងនោះមិនគួរទទួលថ្នាំវ៉ាក់សាំងគ្រុនស្វិតដៃជើងលេបទេ(OPV)។
- ទារកមិនគួរទទួលថ្នាំវ៉ាក់សាំងគ្រុនស្វិតដៃជើងទេ (OPV) បើសិននរណាម្នាក់ដែលបានប៉ះពាល់ក្មេងនោះជិតដិត (ដូចជាជួរកន្ទបជាដើម) មិនធ្លាប់ទទួលថ្នាំគ្រុនស្វិតដៃជើង។
- នរណាម្នាក់ដែលធ្លាប់ធ្វើទុក្ខខ្លាំងពីការប្រើថ្នាំលេបគ្រុនស្វិតដៃជើង មិនគួរទទួលថ្នាំវ៉ាក់សាំងគ្រុនស្វិតដៃជើងលេបទេ(OPV)។

អ្នកទាំងនេះគួររង់ចាំ:

- នរណាម្នាក់ដែលឈឺខ្លាំងនៅពេលត្រូវឲ្យលេបថ្នាំគ្រុនស្វិតដៃជើង (OPV) គួររង់ចាំឲ្យជាសាសស្បើយសិនមុននឹងលេបថ្នាំគ្រុនស្វិតដៃជើង។ មនុស្សឈឺតិចតួច, ដូចជាផ្ដាសសាយ, *អាច*ឲ្យលេបថ្នាំនេះបាន។

សួរទៅមន្ទីរពេទ្យចំពោះពត៌មានច្រើនទៀត។

## 6 តើគ្រោះថ្នាក់លេបថ្នាំគ្រុនស្វិតដៃជើង, OPV, យ៉ាងណា?

OPVតាមពិតអាចធ្វើឲ្យកើតរោគគ្រុនស្វិតដៃជើង,តែកម្រមាន។ ហេតុដូច្នេះហើយបានជាមិនតម្រូវឲ្យ ប្រើសំរាប់មនុស្សជាច្រើន។ វាបានបណ្ដាលឲ្យកើតរោគគ្រុនស្វិត ដៃជើងបួនប្រាំនាក់ដែរក្នុងមួយឆ្នាំៗ(ម្នាក់ក្នុងមនុស្ស២,៤លាននាក់ដែលលេបថ្នាំវ៉ាក់សាំងម្ដង) ក្នុងរយៈពេលដែលប្រើថ្នាំវ៉ាក់សាំងនេះ។ OPVអាចបណ្ដាលឲ្យកើតរោគគ្រុនស្វិតដៃជើងចំពោះមនុស្សដែលទទួលថ្នាំវ៉ាក់សាំងឬមានការប៉ះពាល់គ្នាទៅវិញទៅមក។ សព្វថ្ងៃនេះដោយមានការបង្ក្រាបក្នុង សហរដ្ឋ, គ្រូពេទ្យជំនាញជឿថា ថ្នាំចាក់វ៉ាក់សាំងគ្រុនស្វិតដៃ IPV, អាចការពារក្មេងៗនិងមនុស្សធំដូចគ្នាដោយគ្មានការគ្រោះថ្នាក់។

ថ្នាំវ៉ាក់សាំង, ដូចជាថ្នាំផ្សេងទៀត,អាចបណ្ដាលឲ្យមានបញ្ហាធ្ងន់ធ្ងរ, ដូចជាការធ្វើទុក្ខខ្លាំង។ *ការលេបថ្នាំវ៉ាក់សាំងគ្រុនស្វិតដៃជើងដែលបណ្ដាលឲ្យឈឺចាប់ខ្លាំងឬស្លាប់កម្រមានណាស់។*

## 7 ចុះបើសិនជាមានប្រតិកម្មខ្លាំង?

**តើអ្វីដែលខ្ញុំគួររកមើល?**

រកមើលអ្វីៗមិនធម្មតា, ដូចជាប្រតិកម្មប្រឆាំងខ្លាំង, គ្រុនក្ដៅ, ឬអ្វីៗមិនប្រក្រតី, ឬសញ្ញានៃរោគខ្វិន។

បើសិនមានប្រតិកម្មប្រឆាំងកើតឡើង វានឹងអាចកើតឡើងភ្លាមៗពីពីរបីនាទីទៅពីរបីម៉ោងបន្ទាប់ពីលេបថ្នាំ។ សញ្ញានៃប្រតិកម្មប្រឆាំង អាចដូចជាពិបាកដកដង្ហើម, ទន់ខ្សោយ, ស្អកក, ដកដង្ហើមឮ, បេះដូងដើរញាប់, ក្រហួលស្បែក, វិលមុខ, ស្លេកស្លាំង, ហើមបំពង់ក។

បើសិនជាការពិការបានកើតឡើង, វាអាចកើតឡើងពី១អាទិត្យទៅ១ខែបន្ទាប់ពីការឲ្យលេបថ្នាំវ៉ាក់សាំង។ រោគសញ្ញាអាចមានដូចជា៖

- ឈឺសសៃសាច់ដុំ និង កន្ត្រាក់ទាញសសៃ។
- ខ្សោយ
- បាត់បង់នៃការកម្រើកដៃជើង

**តើខ្ញុំគួរតែធ្វើអ្វី?**

- ទូរស័ព្ទទៅវិជ្ជបណ្ឌិត, ឬរកអ្នកជូនទៅពេទ្យភ្លាម។
- ប្រាប់លោកវិជ្ជបណ្ឌិតអ្វីបានកើតឡើង, ពេលវេលាបានកើតឡើង, ហើយចាក់ថ្នាំនៅពេលណា។
- សួរលោកវិជ្ជបណ្ឌិត,ពេទ្យ,ឬ ក្រសួងពេទ្យឲ្យចុះក្នុងក្រដាសប្រព័ន្ធរាយការណ៍ប្រតិកម្មថ្នាំវ៉ាក់សាំង, ឬទូរស័ព្ទទៅVAERS លេខឥតបង់ប្រាក់ដោយខ្លួនឯងលេខ1-800-822-7967 ។

  ការរាយការណ៍ភាពប្រតិកម្ម ជួយឲ្យគ្រូពេទ្យជំនាញរៀនអំពីបញ្ហាដែលអាចបង្កើតបញ្ហាដោយការប្រើថ្នាំវ៉ាក់សាំង។

## 8 កម្មវិធីជាតិសងការគ្រោះថ្នាក់ថ្នាំវ៉ាក់សាំង

ភាពកម្រមានដែលអ្នកនិងកូនមានប្រតិកម្មខ្លាំងចំពោះថ្នាំវ៉ាក់សាំង, មានកម្មវិធីរដ្ឋដែលអាចជួយបង់ថ្លៃព្យាបាលអ្នកទទួលគ្រោះថ្នាក់។

ចំពោះពត៌មានអំពីកម្មវិធីជាតិសងការគ្រោះថ្នាក់ថ្នាំវ៉ាក់សាំង, (National Vaccine Injury Compensation Program) ចូរទូរស័ព្ទ 1-800-338-2382 ឬមើលកម្មវិធីក្នុង កុំព្យូទ័រ http://www.hrsa.gov/osp/vicp/

## 9 តើខ្ញុំអាចដឹងច្រើនទៀតរបៀបណា?

- ចូរសួរទៅលោកវិជ្ជបណ្ឌិតឬពេទ្យ។ គេអាចប្រាប់អ្នករបៀបចាក់ថ្នាំវ៉ាក់សាំងគ្រប់ចំនួន ឬប្រាប់ឲ្យទៅរកកន្លែងផ្សេងទៀត។
- ទូរស័ព្ទទៅក្រសួងសុខភាពខាងកម្មវិធីចាក់ថ្នាំប្រចាំតំបន់ឬរដ្ឋ។
- ចូរទាក់ទងមណ្ឌលបង្ក្រាបនិងការពារជម្ងឺ(CDC)។
  - ចូរទូរស័ព្ទលេខ 1-800-232-2522 (ភាសារអង់គ្លេស)
  - មើលក្នុងកុំព្យូទ័រកម្មវិធីជាតិ http://www.ede.gov/nip

CDC
CENTERS FOR DISEASE CONTROL AND PREVENTION

U.S. DEPARTMENT OF HEALTH & HUMAN SERVICES
Centers for Disease Control and Prevention
National Immunization Program

Vaccine Information Statement - Khmer
Polio - OPV Supplement (1/1/2000) 42 U.S.C. § 300aa-26

Translation provided by the Minnesota Department of Health